# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ ៨៨៧,០៩៧ ដុល្លារអាមេរិកដើម្បី បង្កើនសមត្ថភាពបោសសម្អាតមីនសម្រាប់ CMAC



ក្រោមគ្រោងការណ៍នៃ ជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោង របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន៨៦,០៤៨,៤០៩ យ៉េន (ប្រមាណជា៨៨៧,០៩៧ដុល្លាអាមេរិក) ដល់អង្គការសកម្មភាពកំចាត់មីនជប៉ុន (JMAS)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស៊ីមម្បូ ស៊ុស៊ុមី ប្រធានតំណាងអង្គការ JMAS ដើម្បីអនុវត្ត "គម្រោងបង្កើនសមត្ថភាពបោសសម្អាតមីនសម្រាប់ CMAC"។

គម្រោងនេះគឺដើម្បីរៀបចំកម្មវិធីសិក្សាថ្មី "ការរួមបញ្ចូលគ្នាវគ្គហ្វឹកហ្វឺនបោសសំអាតមីន" ដើម្បីបង្រៀនអំពីវិធីដោះមីនប្រកបដោយប្រសិទ្ធិភាព ដោយរួមបញ្ចូលរវាងម៉ាស៊ីននិងកំលាំងមនុស្ស ដល់កងអនុសេនាតូចបោសសម្អាតមីនរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) នៅឃុំថែងមានជ័យ ក្នុងស្រុកបាណន់ខេត្តបាត់ដំបង ក្រោមជំនួយបច្ចេកទេសពីទីប្រឹក្សារបស់ JMAS។ ជាងនេះទៅទៀត ជាផ្នែកមួយនៃការផ្ទេរបច្ចេកទេស កងអនុសេនាតូចដែលទទួលការបណ្តុះបណ្តាលដោយ JMAS នៅក្នុងគម្រោងលើកមុននឹងត្រូវក្លាយជាកងអនុសេនាតូចគំរូ។ កងអនុសេនាតូចនេះរំពឹងថានឹងដើរតួនាទីយ៉ាងសំខាន់ដើម្បីរួមចំណែកដល់កិច្ចសហប្រតិបត្តិការត្បូង-ត្បូង។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ក្រុមបោសសម្អាតមីន CMAC ប្រមាណ៤០០នាក់ និង ប្រជាជនប្រមាណ៥,៩០០នាក់ ដោយកាត់បន្ថយការគំរាមកំហែងពីគ្រាប់មីន និងឈានទៅដល់ការអភិវឌ្ឍសហគមន៍ នៅពេលដែលតំបន់នោះត្រូវបានដោះមីនរួច។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង២១.៤ លាន ដុល្លាអាមេរិកដល់គម្រោងចំនួន ៧៩ គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និង សកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី១តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៤របស់ជប៉ុន(មេសា២០១៤ដល់មិនា២០១៥)។









ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp